ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ......៦៣៨......អ.ន.ក

ថ្ងៃ...ចន្ទ...៩...កើត...ខែ...មាឃ...ឆ្នាំ...ច...សំរឹទ្ធិស័ក...ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ...កុម្ភៈ......ឆ្នាំ២០១៩

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែមករា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែមករា ឆ្នាំ២០១៩ មានដូចខាងក្រោម៖

I.**លទ្ធផលបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៨** (គិតត្រឹមថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៧១.៥៦៨ ហ.ត ស្មើនឹង១២៧,៧២ % នៃផែនការចំនួន ៤៤៧.៥០០ ហ.ត លើសជាងឆ្នាំមុនចំនួន ៩២.២៥៥ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៦១០.០៩៩ហ.ត លើសជាងឆ្នាំមុនចំនួន ១០៨.៩០៣ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៦០៣.១៦៣ ហ.ត ស្មើនឹង៩៨,៨៦ % នៃផ្ទៃដីភ្ជួររាស់សរុប
- ផ្ទៃដីសាបសរុប : ១៦៩ ហ.ត យឺតជាងឆ្នាំមុនចំនួន ២៩៣ ហ.ត។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៥-២០១៩ គិតត្រឹម ចុងខែមករានៃឆ្នាំ*

- ប្រៀបធៀបផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងរយៈពេល៥ឆ្នាំចុងក្រោយ គិតត្រឹមចុងខែមករា បង្ហាញថាទាំងផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៨ -២០១៩ អនុវត្តបានច្រើនជាងបណ្តាឆ្នាំមុនៗ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ៣០.៧៩៥ ហ.ត លើសជាងឆ្នាំមុនចំនួន ៤.០៧២ ហ.ត។

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ៧៣.៩១០ ហ.ត លើសជាងឆ្នាំមុនចំនួន ២១.០៧៧ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427